ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ ៥២១.៧១ ប្រក

ភ្នំពេញ ថ្ងៃទី ២៥ ខែ ១០ ឆ្នាំ ២០០២

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការអភិវឌ្ឍន៍ព្រំដែន

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ១៦អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-បានឃើញប្រកាសលេខ ០៩៥ប្រក ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ចរចនាសម្ព័ន្ធរបស់ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បានឃើញលិខិតលេខ ៩៤៩ សជណ សរ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញប្រកាសលេខ ១០០៩ សសរ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការកិច្ចការព្រំដែនរបស់ក្រសួងមហាផ្ទៃ

-តាមការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មការអភិវឌ្ឍន៍ព្រំដែន ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **សេង សេដ្ឋា** | អគ្គនាយករដ្ឋបាល | ប្រធាន |
| ២-ឧត្តមសេនីយ៍ឯក | **គីម សំណាង** | អគ្គស្នងការរងនគរបាលជាតិ | អនុប្រធាន |
| ៣-ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល និង ឯកឧត្តមអភិបាលខេត្ត ក្រុង ដែលជាប់ព្រំដែនគោក | | | សមាជិក |
| ៤-លោក | **អ៊ឹម សារូ** | អគ្គនាយករងរដ្ឋបាល | សមាជិក |
| ៥-ឧត្តមសេនីយ៍ទោ | **ភ៊ិន ឆន** | ប្រធាននាយកដ្ឋានកិច្ចការព្រំដែន | សមាជិក |

៦-ឧត្តមសេនីយ៍ទោ ចាន់ ហឿន ប្រធាននា. ព្រំដែនគោក សមាជិក

៧-ឧត្តមសេនីយ៍ត្រី គឹម ស៊ើមម៉ៃ ប្រធាននា. បច្ចេកទេសព្រំដែន សមាជិក

៨-ឧត្តមសេនីយ៍ត្រី ឡៅ សុខឃី ប្រធាននា. ព្រំដែនទឹក សមាជិក

៩-លោក ហួយ គឹមឡុនៈ ប្រធាននា.រដ្ឋបាលទូទៅ សមាជិក

១០-លោក ឡាយ ចោមរឹទ្ធិ ប្រធាននា. កិច្ចការនយោបាយ សមាជិក

១១-លោក ទី សុភជាន អនុប្រធានទី១ នា.កិច្ចការនយោបាយ សមាជិក

១២-លោក ជាក សោធី អនុប្រធានទី១ នា. រដ្ឋបាលទូទៅ សមាជិក

១៣-លោក អុច មន្តរុយ អនុប្រធាននា. រដ្ឋបាលទូទៅ សមាជិក

១៤-លោក ឆោវ ថែន ប្រធានលេខាធិការដ្ឋាននៃអគ្គនាយកដ្ឋានរដ្ឋបាល សមាជិក

**ប្រការ២ :** បង្កើតក្រុមការងារមួយក្រុមទទួលការងារជំនាញ ជាជំនួយការផ្ទាល់របស់គណៈកម្មការអភិវឌ្ឍន៍ព្រំដែន រួមមានសមាសភាពដូចខាងក្រោម :

១-លោក អ៊ុច មន្តរុយ អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ ប្រធាន

២-លោក ញ៉ឹ ឃឹម អនុប្រធាន នាយកដ្ឋានកិច្ចការនយោបាយ អនុប្រធាន

៣-ឧត្តមសេនីយ៍ត្រី វេត ឡុច អនុប្រធាននាយកដ្ឋានគណ្ឌាលព្រំដែន អនុប្រធាន

៤-លោកវរៈសេនីយ៍ឯក ង៉ិ សោខលន់ អនុប្រធាននាយកដ្ឋានព្រំដែនគោក អនុប្រធាន

៥-លោកវរៈសេនីយ៍ឯក យ៉ើន សុមណ្ឌ អនុប្រធាននាយកដ្ឋានបច្ចេកទេសព្រំដែន អនុប្រធាន

៦-លោកវរៈសេនីយ៍ឯក ង៉ុ សុគុណ អនុប្រធាននា. ព្រំដែនទឹក អនុប្រធាន

៧-លោកអគ្គលេខាធិការសាលាខេត្ត ក្រុងទាំង១៧ ដែលមានព្រំដែនគោកជាប់ នឹង ប្រទេសវៀតណាម ឡាវ ថៃ អនុប្រធាន

៨-លោក ទេម សុធីរ នាយការិយាល័យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌សាសនា នា.រដ្ឋបាលទូទៅ សមាជិក

៩-លោក ជើន យុមនា នាយរងការិយាល័យកិច្ចការនយោបាយ សិទ្ធិមនុស្ស សមាជិក

១០-លោក តរុស ផ្កាថ៊ា នាយរងការិយាល័យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ សាសនា នា.រដ្ឋបាលទូទៅ សមាជិក

| | | | |
|---|---|---|---|
| ១១-លោក | **កែ រិទ្ធី** | មន្ត្រី នា.រដ្ឋបាលទូទៅ | សមាជិក |
| ១២-លោក | **ឆុំ ចាន់ឌី** | មន្ត្រី នា.រដ្ឋបាលទូទៅ | សមាជិក |
| ១៣-លោក | **ឈី ធីរៈ** | មន្ត្រី នា.រដ្ឋបាលទូទៅ | សមាជិក |

**ប្រការ៣ :** គណៈកម្មការនេះ មានភារកិច្ចលើកគំរោងផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅតាមព្រំដែន កម្ពុជា-ឡាវ កម្ពុជា-វៀតណាម និង កម្ពុជា-ថៃ សំដៅបង្កលក្ខណៈងាយស្រួលអោយប្រជាពលរដ្ឋអាចមានលទ្ធភាពរស់នៅ និង រួមចំណែកការពារព្រំដែន និង លើកសំណើនានាដាក់ជូនថ្នាក់ដឹកនាំ ក្រសួងពិនិត្យ និង សំរេច ដើម្បីត្រៀមសហការជាមួយក្រសួងសាធារណការ និង ដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងការពារជាតិ អគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទនិងក្រសួងស្ថាប័នពាក់ព័ន្ធ ។

**ប្រការ៤ :** ប្រកាសលេខ ១០០៩ សស.រ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការកិច្ចការព្រំដែន ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥ :** អគ្គលេខាធិការ អគ្គនាយករដ្ឋបាល អគ្គស្នងការនគរបាលជាតិ ប្រធាននាយកដ្ឋាន ផែនការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ឯកឧត្តម អស់លោក ដែលមានសមាសភាពក្នុងប្រការ១ និង ប្រការ២ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ។

**ប្រការ៦ :** ប្រកាសនេះចូលជាធរមានចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**សហរដ្ឋមន្ត្រី**

ស ខេង                យូ ហុកគ្រី

*ចំលងជូន*

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួង ស្ថាប័ន ពាក់ព័ន្ធ
-គ្រប់សាលាខេត្ត ក្រុង
-ដូចប្រការ៥
-សាមីខ្លួន
-ឯកសារ កាលប្បវត្តិ